# ជម្ងឺកាមរោគ

## (Sexually transmissible infections)

**ការព្យាបាលគឺជាការប្រសើរ / ការបង្ការគឺជាការល្អបំផុត**

ខែកក្កដា ឆ្នាំ 2003

Cambodian

### អ្វីដែលយើងទាំងអស់គ្នាត្រូវដឹង

ជនរាល់រូបដែលរួមរ័កយ៉ាងសកម្ម ត្រូវដឹងអំពីជម្ងឺកាមរោគ (STIs) និងរបៀបល្អបំផុតដើម្បីការពារទល់នឹងជម្ងឺនេះ។ ផលវិបាកនៃជម្ងឺកាមរោគ

អាចមានភាពធ្ងន់ធ្ងរណាស់ចំពោះខ្លួនយើង និងនរណាម្នាក់ដែលយើងរួមរ័កជាមួយ។

មនុស្សជាច្រើនមានអារម្មណ៍ច្របល់គ្នានៃការភ័យខ្លាច កំហឹង និង អាម៉ាស់មុខ។ ភាពខ្មាស់អៀនក៏អាចបញ្ឈប់មិនឲ្យគេរកជំនួយដែរ។ ការរង់ចាំនិងការបារម្ភ មិនដែលជាគំនិតល្អទេ ហើយទោះជាមានសញ្ញាថា ជម្ងឺនេះបានបាត់ទៅហើយក្តី ក៏លោកអ្នកអាចនៅមានជម្ងឺនេះនៅឡើយ។

វេជ្ជបណ្ឌិតព្យាបាលជម្ងឺកាមរោគគ្រប់ពេលទាំងអស់ ហើយពត៌មានអំពីលោកអ្នកនឹងត្រូវរក្សាទុកជាសម្ងាត់។ គ្លីនិកពិសេសទាំងឡាយផ្តល់ការថែទាំល្អក្រៃលែងដោយឥតគិតថ្លៃ។ សូមមើលនៅក្នុងបញ្ជីរាយឈ្មោះគ្លីនិក។

### តើអ្វីទៅដែលជាជម្ងឺកាមរោគ?

ជម្ងឺកាមរោគ ជាជម្ងឺមួយដែលអាចឆ្លងក្នុងអំឡុងការរួមរ័កដែលគ្មានវិធីការពារ ដោយមាននរណាម្នាក់កើតមានជម្ងឺកាមរោគរួចហើយ។ "ការរួមរ័កដែលគ្មានវិធីការពារ"គឺជាការរួមរ័កដែលគ្មានរបាំងការពារ (ឧទាហរណ៍: ស្រោមអនាម័យ ឬ dam "របាំង") ដើម្បីបង្ការកុំឲ្យមានការលាយឡំគ្នានូវអង្គធាតុទឹកនៃរាងកាយ (ឈាម ទឹកកាម ឬ ទឹករំអិលនៃយោនី) រវាងដៃគូរួមរ័ក។ ការប្តូរគ្នាទៅវិញ ទៅមកនៃអង្គធាតុទឹកទាំងនេះអាចកើតមានឡើង នៅពេលដែលមានការស៊កលិង្គ ឬប្រដាប់រួមរ័ក ដែលប្រើរួមគ្នាហើយដែលគ្មានស្រោមអនាម័យ ទៅក្នុងទ្វារមាស រន្ធគូថ ឬ មាត់។

អតិសុខុមប្រាណតូចៗ ដូចជាវីរុស បាក់តេរី ឬប៉ារ៉ាស៊ីត បង្កឲ្យមានជម្ងឺកាមរោគភាគច្រើន។ អតិសុខុមប្រាណខ្លះ ដូចជាថៃនៃអង្គជាតិ និងឬសដុះលើស្បែក រស់នៅលើផ្ទៃស្បែក ហើយអាចចម្លងទៅកាន់ជនម្នាក់ទៀត តាមរយៈការប៉ះស្បែកនឹងស្បែក។

ជម្ងឺកាមរោគអាចបណ្តាលឲ្យមានបញ្ហាមួយចំនួនផ្សេងគ្នា ចាប់ពីការរមាស់មិនសូវខ្លាំងរហូតដល់ជម្ងឺធ្ងន់ធ្ងរ ដែលមានផលប៉ះពាល់រយៈពេលយូរ។ បើមិនព្យាបាលទេ ជម្ងឺខ្លះអាចបណ្តាលឲ្យស្ត្រីនិង បុរសមិនអាចផ្តល់កំណើតកូនបានឡើយ។

ជម្ងឺកាមរោគជាច្រើនមានរោគសញ្ញាដែលលោកអ្នកអាចកត់សំគាល់ឃើញ ហើយលោកអ្នកគួរទទួលឱវាទពីគ្រូពេទ្យ មួយរំពេច។ ទោះដូច្នេះក្តី ក៏ជួនកាលទៅ លោកអ្នកមិនកត់សំគាល់ឃើញរោគសញ្ញាច្បាស់លាស់ឡើយ ដូច្នេះវាជាការសំខាន់ណាស់ដែលឲ្យគ្រូពេទ្យឆែកពិនិត្យមើលបើលោកអ្នកគិតថា លោកអ្នកប្រហែលជាកើតមានជម្ងឺកាមរោគមួយ។

- ជម្ងឺកាមរោគភាគច្រើន អាចព្យាបាលបាន។
- ជម្ងឺកាមរោគដែលគេមិនអាចព្យាបាលបានឥឡូវនេះគេអាចគ្រប់គ្រងវាបានយ៉ាងល្អ។

### តើលោកអ្នកឆ្លងជម្ងឺកាមរោគពីនរណា?

លោកអ្នកមិនអាចដឹងថា តើដៃគូរួមរ័កមានជម្ងឺកាមរោគដែរឬទេ។ ជនទាំងឡាយអាចមើលទៅមានសុខភាពល្អ ប៉ុន្តែនៅតែអាចកើតរោគដែរ។ ជនម្នាក់ប្រហែលជាមិនដឹងថា ខ្លួនមានជម្ងឺកាមរោគឡើយ។

លោកអ្នកមានលទ្ធភាពគ្រោះថ្នាក់កើតជម្ងឺកាមរោគពីដៃគូណាមួយដែលបាន ឬ កំពុងរួមរ័កដោយគ្មានសុវត្ថិភាព ជាមួយនឹងជនម្នាក់ទៀត។

### តើខ្ញុំអាចបង្ការកុំឲ្យកើតជម្ងឺនេះដែរឬទេ?

អាចធ្វើបាន ដោយអនុវត្ត"ការរួមរ័កដោយសុវត្ថិភាព"។ បទបញ្ញត្តិជាគោលការណ៍គឺការចៀសវាងឈាម ទឹកកាម ឬទឹករំអិលនៃយោនី ពីដៃគូរួមរ័ក កុំឲ្យចូលទៅក្នុងរាងកាយលោកអ្នកលុះត្រាតែលោកអ្នកដឹងប្រាកដថា ដៃគូលោកអ្នកមិនកំពុងកើតជម្ងឺកាមរោគឡើយ។ ឧទាហរណ៍: ការរួមរ័កដោយសុវត្ថិភាពមានរួមទាំងថើបជញ្ជក់មាត់ ការសេពកាមដោយដៃទៅវិញទៅមក និង ការធ្វើសរសៃធ្វើឲ្យស្រើបស្រាល។

ការពារខ្លួនលោកអ្នកនិងអ្នកដទៃ ដោយ:

- ប្រើឲ្យត្រឹមត្រូវនូវស្រោមអនាម័យនិងប្រេងរំអិលផលិតពីជាតិទឹក ជាមួយនឹងដៃគូរួមរ័កទាំងអស់។
- រួមរ័កដោយសុវត្ថិភាព ដោយគ្មានប៉ះនឹងអង្គធាតុទឹកនៃការរួមរ័ក។
- កុំរួមរ័ក។

ការរួមរ័កដែលគ្មានវិធីការពារ ជាមួយនឹងដៃគូប្រក្រតី អាចមានសុវត្ថិភាព បើ:

- លោកអ្នកទាំងពីរ បានធ្វើតេស្តពេញលេញដោយបញ្ជាក់ថាគ្មានជម្ងឺកាមរោគ ហើយគ្មាននរណាម្នាក់ រួមរ័កជាមួយជនណាមួយផ្សេងទៀត; ហើយ
- បើលោកអ្នកត្រូវការកិច្ចការពារកុំឲ្យមានផ្ទៃពោះ លោកអ្នកត្រូវប្រើវិធីការពារកំណើតកូនតាមប្រភេទខ្លះទៀត។

សូមពិភាក្សាជាមួយដៃគូលោកអ្នក បើលោកអ្នកមានអារម្មណ៍មិនប្រាកដទេនោះ សូមទទូចឲ្យ"រួមរ័កដោយសុវត្ថិភាព"។

បើលោកអ្នកទាំងពីរយល់ស្របលើការរួមរ័កជាមួយអ្នកដទៃ វាជាការសំខាន់ណាស់ក្នុងការអនុវត្តការ"រួមរ័កដោយសុវត្ថិភាព"ជានិច្ច។

### តើខ្ញុំកំពុងប្រើស្រោមអនាម័យដោយសមរម្យឬទេ?

ចូរធ្វើឲ្យប្រាកដថា លោកអ្នក:

- ទុកស្រោមអនាម័យនៅក្នុងកន្លែងត្រជាក់ស្ងួត កុំឲ្យត្រូវចំពន្លឺថ្ងៃ។
- ប្រើតែស្រោមអនាម័យនៅមុនថ្ងៃហួសកំណត់ប៉ុណ្ណោះ។
- បើកកញ្ចប់ដោយប្រុងប្រយ័ត្ន និងក្រោមពន្លឺល្អ ដើម្បីកុំឲ្យរហែកដល់ស្រោមអនាម័យ។ ច្បិចច្របាច់ខាងចុងស្រោមនេះ ហើយ ប្រមៀលវាដោយប្រុងប្រយ័ត្នចុះដល់គល់ "លិង្គដែលរឹង។
- ប្រើប្រេងរំអិលផលិតពីជាតិទឹកឲ្យបានច្រើន ជាពិសេសការរួមរ័កតាមរន្ធគូថ។ ការរួមរ័កដោយគ្មានប្រេងរំអិល អាចបណ្តាលឲ្យស្រោមអនាម័យរហែក។ ចូរ

កុំប្រើប្រេងរំអិលផលិតពីជាតិប្រេង ដូចជាប្រេងកូនក្មេង ឬ ប្រេងអន្លិលជាតិប្រេងកាត ដែលធ្វើឲ្យស្រោមអនាម័យបាត់បង់គុណភាព។

- ធ្វើឲ្យប្រាកដថា ត្រូវដកលិង្គចេញនៅមុនពេលលិង្គទន់ទៅវិញ ដើម្បីកុំឲ្យរបូតស្រោមអនាម័យ។ កាន់ទប់គល់ខាងក្រោមនៃស្រោមនេះ ក្នុងអឡុងពេលដកចេញ ដើម្បីកុំឲ្យហៀរចេញទឹកកាម។
- កុំប្រើស្រោមអនាម័យសាជាថ្មី។ បោះវាចោលទៅក្នុងធុងសម្រាម។
- ប្រើស្រោមអនាម័យដែលយល់ព្រមឲ្យលក់នៅក្នុងប្រទេសអូស្ត្រាលីតែប៉ុណ្ណោះ។ ចៀសវាងស្រោមអនាម័យក្លែងក្លាយ ដែលអាចមានគុណភាពអន់ហើយរហែក។

**តើវិធីណាទៅដែលអាចឲ្យខ្ញុំដឹងថា ខ្ញុំកើតមានជម្ងឺកាមរោគ?**

លោកអ្នកប្រហែលជាមិនកត់សំគាល់ឃើញសញ្ញាទាល់តែសោះ ដែលថាលោកអ្នកមានជម្ងឺកាមរោគ ដូច្នេះលោកអ្នកត្រូវមានការប្រុងប្រយ័ត្នជានិច្ច។

សញ្ញាដែលកើតមាន អាចជា:

- ការចេញអង្គធាតុទឹកពីលិង្គ ឬ ទ្វារមាស។
- ឈឺចាប់ឬក្រហល់ក្រហាយនៅពេលបត់ជើងតូច ឬ ក្នុងអឡុងពេលរួមរ័ក។
- លំបាកបត់ជើងតូច។
- ឈឺផ្សារ ពងទឹក ដំបៅ ដុះបូស ដំ ឬ រោលកន្ទួល នៅកន្លែងណាមួយនៅក្បែរអង្គជាតិ ឬ រន្ធគូថ។
- រមាស់ឬក្រហល់ក្រហាយនៅក្នុងអង្គជាតិ ឬ កន្លែងរន្ធគូថ។
- ចេញឈាមតាមទ្វារមាស ក្រោយពីរួមរ័ក។

**តើខ្ញុំគួរធ្វើអ្វី បើខ្ញុំយល់ថា ខ្ញុំកើតជម្ងឺកាមរោគ?**

ទៅជួបវេជ្ជបណ្ឌិតលោកអ្នកភ្លាមតែម្តង។ ការសង្ស័យថា ជម្ងឺនេះនឹងបាត់ទៅវិញ នឹងពន្យារដល់ ការព្យាបាលឬការធានាសាជាថ្មីនៃការគ្មានជម្ងឺតែប៉ុណ្ណោះ។ សញ្ញាទាំងពួងប្រហែលជាបាត់ទៅវិញ ប៉ុន្តែវាមិនមានន័យថា ជម្ងឺនេះបានបាត់ទៅវិញនោះទេ។ បើលោកអ្នកមានរោគសញ្ញាដែលអាចបណ្តាលដោយជម្ងឺកាមរោគនោះ វាជាការប្រសើរក្នុងការចៀសវាងការរួមរ័ករហូតទាល់តែបន្ទាប់ពីលោកអ្នកបានទៅជួបវេជ្ជបណ្ឌិត ដើម្បីកុំឲ្យលោកអ្នកចម្លងជម្ងឺនេះ។ បើលោកអ្នករួមរ័ក លោកអ្នកត្រូវពាក់ស្រោមការពារ។

**ធ្វើឲ្យមានសុវត្ថិភាព**

ការមិនប្រើស្រោមអនាម័យដោយសារតែការផឹកស្រាឬប្រើគ្រឿងញៀន ឬកង្វះខាតសេចក្តីក្លាហាន ដើម្បីបញ្ជាក់នូវសិទ្ធិលោកអ្នកក្នុងការការពារខ្លួនលោកអ្នក អាចធ្វើឲ្យលោកអ្នកមានគ្រោះថ្នាក់។

ការថែទាំខ្លួនលោកអ្នកមានន័យថា ដឹងនូវពេល និងរបៀបនិយាយថា"ទេ" និងសេចក្តីក្លាហាន ដើម្បីទទូចឲ្យប្រើស្រោមអនាម័យ។ ផ្នែកនៃការរួមរ័កដោយសុវត្ថិភាព ក៏ធ្វើឲ្យប្រាកដផងដែរថា អ្វីដែលលោកអ្នកធ្វើនិងជនដែលលោកអ្នកធ្វើជាមួយ គឺជាអ្វីៗដែលលោកអ្នកសំរេច។

**តើជម្ងឺកាមរោគអ្វីទៅដែលមានភាពទូទៅបំផុត?**

- ជម្ងឺក្លាមីឌៀ (chlamydia)
- ជម្ងឺអែរប៉េស (genital herpes)
- ជម្ងឺដុះបូសនៅនឹងអង្គជាតិ
- ជម្ងឺប្រមេះទឹកបាយ
- ជម្ងឺរលាកថ្លើមប្រភេទ B
- HIV និង AIDS
- ចៃនៅនឹងថ្ងាសអង្គជាតិ
- Syphilis (រោគស្វាយ)
- Trichomonas (ជម្ងឺរលាកអង្គជាតិបង្កដោយទ្រីកូម៉ូណាស់)

**ជម្ងឺទាក់ទងផ្សេងទៀត:**

ជម្ងឺទាំងនេះ មានរួមទាំងជម្ងឺអង្គជាតិដែលអាចត្រូវការការព្យាបាល។ ជម្ងឺទាំងនេះមិនចាំបាច់ជាជម្ងឺកាមរោគទេ ប៉ុន្តែវាអាចកើតមានដោយសារតែការរួមរ័ក។

- Bacterial Vaginosis (ជម្ងឺទ្វារមាសបង្កដោយបាក់តេរីម៉្យាង)
- ជម្ងឺរលាកថ្លើមប្រភេទ C
- ជម្ងឺរលាកផ្លូវនោមមិនជាក់លាក់ (NSU)
- THRUSH (ជម្ងឺប្រាំង)

**តើត្រូវការជំនួយ / ពត៌មានបន្ថែមឬ?**

សូមទៅជួបវេជ្ជបណ្ឌិតលោកអ្នក បើលោកអ្នកអាចនិយាយដោយមិនលាក់លៀមជាមួយគាត់។ ជម្ងឺកាមរោគគឺជាជម្ងឺទូទៅ ហើយវេជ្ជបណ្ឌិតភាគច្រើនមានបទពិសោធន៍ច្រើននៅក្នុងផ្នែកនេះ។ ថ្លៃព្យាបាលនិងការចុះថ្លៃថម្ងតា អាចអនុវត្តសំរាប់ជម្ងឺកាមរោគ។

បើលោកអ្នកមានអារម្មណ៍មិនកក់ក្តៅអំពីការទៅជួបវេជ្ជបណ្ឌិតប្រក្រតីរបស់លោកអ្នក សូមទូរស័ព្ទទៅកាន់សេវាពត៌មានឥតគិតថ្លៃ តាមរយៈ:

**The Melbourne Sexual Centre**
**580 Swanston St. Carlton**
ទូរស័ព្ទ: 9347 0244
(រួមទាំង TTY សំរាប់អ្នកថ្លង់)
ទូរស័ព្ទឥតគិតថ្លៃសំរាប់តំបន់ជនបទ
1800 032 017

សេវាទាំងអស់ឥតគិតថ្លៃ និងលាក់ការសម្ងាត់។ បុគ្គលិកធ្វើការអាចផ្តល់ជូនលោកអ្នកនូវឱវាទថ្មីបំផុតតាមទូរស័ព្ទ ធ្វើការណាត់ជួបជាមួយលោកអ្នក ឬបញ្ជូនលោកអ្នក ទៅជួបវេជ្ជបណ្ឌិតក្នុងតំបន់លោកអ្នក។

ទំព័របន្ទាប់នេះផ្តល់ពត៌មានពេញលេញនៃសេវាដែលមាន។

**សេវាទូទាំងរដ្ឋ និង ពត៌មានសំរាប់ទាក់ទង:**

**AIDSLINE**
ផ្តល់ការពិគ្រោះឱវាទតាមទូរស័ព្ទ អំពី HIV/AIDS, STIs និងសុខភាពនៃការរួមរ័ក។
ទូរស័ព្ទ 9347 6099
ទូរស័ព្ទឥតគិតថ្លៃពីជនបទ
1800 133 392
TTY 1800 032 665

**Hepatits C Helpline**
ផ្តល់ការពិគ្រោះឱវាទ ពត៌មាន និង ការបញ្ជូនតាមទូរស័ព្ទ។
ទូរស័ព្ទ 9349 1111
ទូរស័ព្ទឥតគិតថ្លៃពីជនបទ
1800 800 241
និយាភាសាវៀតណាម
1800 456 007
TTY 1800 032 665

**Victoria AIDS Council/Gay Men's Health Centre**
6 Claremont St, South Yarra 3141
ទូរស័ព្ទ 9865 6700
ទូរស័ព្ទឥតគិតថ្លៃ 1800 134 840
TTY 9827 3733
www.vicaids.asn.au

**Access Information Centre at The Alfred**
Commercial Rd
Prahran 3181
ទូរស័ព្ទ 9276 6993
Email:
access@alfred.org.au
www.accessinfo.org.au

**The Centre Clinics**
**C/- Northcote Community Health Centre**
42 Separation St
Northcote 3070
ទូរស័ព្ទ 9481 7155

**St Kilda**
46 Acland St.
St Kilda 3182
ទូរស័ព្ទ 9525 5866

**Family Planning Victoria**
901 Whitehorse Road
Box Hill 3128
គ្លីនិក និង ការអប់រំ
ទូរស័ព្ទ 9257 0100
Email: fpv@fpv.org.au

**Action Centre (Youth)**
Level 1, 94 Elizabeth St
Melbourne 3000
គ្លីនិក និង ការអប់រំ
ទូរស័ព្ទ 9654 4766 ឬ
1800 013 952

**Hepatitis C Council of Victoria**
Suite 5, 200 Sydney Road
Brunswick 3056
ទូរស័ព្ទ 9380 4644
ទូរស័ព្ទឥតិគិតថ្លៃសំរាប់ទីជនបទ
1800 703 003

**គ្លីនិកជម្ងឺកាមរោគនៅតំបន់ជនបទ:**
**The Annexe Sexual Health Family Clinic**
**Ballarat Community Health**
710 Sturt Street
Ballarat 3350
ទូរស័ព្ទ 5333 1635

**STD Clinic - Bendigo Community Health Service**
3 Seymoure Street
Eaglehawk 3556
ទូរស័ព្ទ 5434 4300

**STD Clinic - Barwon Health**
Geelong Hospital
Swanston Street
Geelong 3220
ទូរស័ព្ទ 5221 4735

**STD Clinic - Vermont St Health Clinic**
4 Benson Court
Wodonga 3690
ទូរស័ព្ទ 6056 1589

**STD Clinic - Latrobe Regional Hospital (Outpatient Dept)**
Cnr Princess Highway & Village Way
Traralgon 3844
ទូរស័ព្ទ 5173 8000